**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ..១០៥......សហវ-ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

ទំនិញនាំចូលដោយលើកលែងពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក ក ជា ខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ សម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារនៃកិច្ចសហប្រតិបត្តិការ

បច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការរបស់ខ្លួន និងបុគ្គលិករបស់អង្គការទាំងនេះ ត្រូវនាំចេញទៅវិញបន្ទាប់ពីបញ្ចប់បេសកម្មរបស់ខ្លួន ។

ទំនិញទាំងនេះព្រមទាំងទំនិញផ្សេងទៀតក្រោមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្រោងដែលបានអនុគ្រោះ ឬបោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ២.-**

ទំនិញនាំចូលដោយលើកលែងជាភាគនៃពន្ធ និងអាករនាំចូល ក្រោមបញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្រោងដែលបានអនុគ្រោះ ឬបោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ៣.-**

អង្គការ ឬបុគ្គលនានាដែលមានបំណងលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្រោងដែលបានអនុគ្រោះ ឬបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែង ឬលើកលែងជាភាគនូវពន្ធ និងអាករនាំចូលត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយស្របតាមនីតិវិធីដូចខាងក្រោម ៖

ក. ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតមករដ្ឋបាលគយ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីរបៀបនៃការប្តូរគម្រោង ឬការប្តូរកម្មសិទ្ធលើទំនិញនេះ ។ ច្បាប់ចម្លងនៃពាក្យស្នើសុំនេះត្រូវផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ទំនិញដែលនាំចូលក្រោមបញ្ញត្តិកថាខណ្ឌទី ១ ប្រការ ១ នៃប្រកាសនេះ ។

ខ. ពាក្យស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារផ្សេងទៀតប្រសិនបើមាន ។ ទំនិញពុំត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ ឬបង្វែរមុនពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឡើយ ។

គ. កម្មសិទ្ធិករថ្មីត្រូវទទួលខុសត្រូវលើការបង់ពន្ធ និងអាករជូនរដ្ឋបាលគយតាមនីតិវិធីគយជាធរមាន ។ ទំនិញពុំអាចត្រូវបានប្រគល់ជូនកម្មសិទ្ធិករថ្មីដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ និងមុនពេលបង់ពន្ធ និងអាករដែលជាប់ ឬទទួលបានការលើកលែងពន្ធជាថ្មីពីស្ថាប័នមានសមត្ថកិច្ច ។

ឃ. រដ្ឋបាលគយត្រូវគិតគូរពីលក្ខខណ្ឌជាក់ស្តែង និងសភាពនៃទំនិញទាំងនោះនាពេលប្រគល់ទទួល និងអាចកែសម្រួលតម្លៃគិតពន្ធគយតាមនេះ ។

**ប្រការ ៤.-**

ទំនិញដែលមានប្រភពក្នុងដែនគយ ឬដែលបាននាំចូលដោយបង់ពន្ធ និងអាកររួច ឬដែលនាំចូលត្រឡប់មកវិញពីបរទេសដោយពុំមានបន្ថែមតម្លៃ ត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់ ឬបោះបង់ចោលដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ ៥.-**

អង្គការ ឬបុគ្គលនានាដែលមានបំណងបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែងពន្ធ និងអាករនាំចូល ត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។ ការស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត ។

ការបោះបង់ចោលទំនិញអាចធ្វើឡើងតែក្រោយពេលមានការអនុញ្ញាតពីរដ្ឋបាលគយ ។ រដ្ឋបាលគយអាចឃ្លាំមើលការបោះបង់ចោល ឬការបំផ្លាញទំនិញទាំងនេះ ។

**ប្រការ ៦.-**

ទីចាត់ការគយ និងរដ្ឋាករមានភារកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវបញ្ញត្តិប្រការ ១ និងប្រការ ៣ នៃប្រកាសនេះ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៨
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ